# អ្វីទៅជាការអភិវឌ្ឍសមត្ថភាព?

## What is Capacity Development?

Prepared and presented by:
*Leng Chhay*
Organizational Development Consultant
E-mail: learning@camlefa.org
Website: www.camlefa.org

# សមត្ថភាព (Capacity)

- ជាលទ្ធភាព (ability) របស់មនុស្ស អង្គការ និងសង្គម ក្នុងការគ្រប់គ្រងដំណើរការអភិវឌ្ឍរបស់គេ ប្រកបដោយចីរភាព ។ (GTZ)
- ជាលទ្ធភាពរបស់បុគ្គលម្នាក់ៗ ស្ថាប័ន និងសង្គម ក្នុងការអនុវត្តមុខងារនានា ដោះស្រាយបញ្ហា និងកំណត់និងសម្រេចគោលបំណង ប្រកបដោយ ចីរភាព។ (UNDP)

# ការអភិវឌ្ឍសមត្ថភាព (Capacity Development)

- ការអភិវឌ្ឍសមត្ថភាពជាដំណើរការគ្រប់ជ្រុងជ្រោយ ដែលតាមរយៈដំណើរការនោះ បុគ្គល/មនុស្ស អង្គការ និងសង្គម ធ្វើការគៀងគរ ថែរក្សា ផ្លាស់ប្តូរ និងពង្រីកលទ្ធភាពរបស់គេ ក្នុងការគ្រប់គ្រងការអភិវឌ្ឍផ្ទាល់ខ្លួនរបស់គេ ប្រកបដោយចីរភាព។ (GTZ)
- ការអភិវឌ្ឍសមត្ថភាពជាដំណើរការ ដែលក្នុងនោះ បុគ្គល អង្គការ/ស្ថាប័ន និងសង្គម ទទួលបាន ពង្រឹង និងរក្សា នូវសមត្ថភាពក្នុងការកំណត់ និងសម្រេចគោលបំណងអភិវឌ្ឍន៍របស់គេ ជាបន្តបន្ទាប់។ (UNDP)

# ការកសាង និងអភិវឌ្ឍសមត្ថភាព

- ការកសាងសមត្ថភាព (Capacity Building) សំដៅទៅលើដំណើរការមួយ ដែលគាំទ្រលើដំណាក់ដំបូងនៃការកសាង ឬបង្កើតសមត្ថភាពតែប៉ុណ្ណោះ ជាមួយនឹងការសន្មតថា ពុំទាន់មានសត្ថភាពដែលមានស្រាប់ឡើយក្នុងការចាប់ផ្ដើម។
- ការអភិវឌ្ឍសមត្ថភាព (Capacity development) សំដៅលើដំណើរការនៃការបង្កើត និងកសាងសមត្ថភាព និងការប្រើប្រាស់ គ្រប់គ្រង និង ការថែរក្សាបន្តបន្ទាប់នៃសមត្ថភាពទាំងនោះ។ ដំណើរការនេះត្រូវបានជំរុញដោយផ្នែកខាងក្នុង និងចាប់ផ្តើម ចេញពីសមត្ថភាពដែលមានស្រាប់។ (UNDP)

# លំដាប់នៃសមត្ថភាព

**ក្របខ័ណ្ឌគាំទ្រ**

**អង្គការ**

**បុគ្គល**

ក្របខ័ណ្ឌគាំទ្រ

ជាបរិយាកាសគាំទ្រ និងលក្ខខណ្ឌនានា ដែលតម្រូវឲ្យមានសម្រាប់ធ្វើឲ្យសមត្ថភាពកម្រិតបុគ្គលនិងកម្រិតអង្គការអាចប្រព្រឹត្តិទៅបាន។ ផ្លូវការ៖ បទបញ្ញា ច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តិនានា។ ក្រៅផ្លូវការ៖ ទម្លាប់ ប្រពៃណី និងបទដ្ឋានសង្គម ប្រពៃណី ក្រមសីលធម៌។

អង្គការ/ស្ថាប័ន

គោលដៅ យុទ្ធសាស្ត្រ រចនាសម្ព័ន្ធ ប្រព័ន្ធ គ្រប់គ្រង ការដឹកនាំ ការប្រាស្រ័យទាក់ទង ដំណើរការធ្វើសេចក្ដីសម្រេច ធនធាន/ទ្រព្យសម្បត្តិ ។ល។ ដែលកំណត់ប្រសិទ្ធភាព អង្គការ/ស្ថាប័នមួយ

បុគ្គល

ចំណេះដឹង ជំនាញ និងអាកប្បកិរិយា តម្រូវអោយបុគ្គលម្នាក់មានសម្រាប់អនុវត្តមុខនាទីរបស់គេ (ដូចជា ជំនាញហិរញ្ញវត្ថុ លទ្ធកម្ម ព័ត៌មានវិទ្យា បណ្ដុះបណ្ដាល ។ល។




កម្រិតទាំងបីនៃសមត្ថភាពរួមគ្នា ឈានទៅសម្រេចបានលទ្ធផលការងាររបស់ស្ថាប័ន